ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

CAMBODIA
Kingdom of Wonder
feel the warmth

ក្រសួងទេសចរណ៍

លេខ ០៥០ សសរ

ថ្ងៃ អង្គារ ៩រោច ខែ ស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០២១

# សេចក្ដីសម្រេច

## ស្ដីពី

## ការដាក់ឱ្យអនុវត្តនីតិវិធីប្រតិបត្តិស្តង់ដារអប្បបរមា តាមគន្លងប្រក្រតីភាពថ្មីសម្រាប់អាជីវកម្មភោជនីយដ្ឋានទេសចរណ៍

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំងនិងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២១/០០៤ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញអនុក្រឹត្យលេខ ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៣៧ អនក្រ.បក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ស្ដីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ ស្ដីពីវិធានការរដ្ឋបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត

## សម្រេច

**ប្រការ១ .–**

ត្រូវបានដាក់ឱ្យអនុវត្តនីតិវិធីប្រតិបត្តិស្តង់ដាអប្បបរមា (Minimum Standard of Operation - MSOP) តាមគន្លងប្រក្រតីភាពថ្មីសម្រាប់អាជីវកម្មរមណីយដ្ឋានទេសចរណ៍ ដែលជាឧបសម្ព័ន្ធនៃសេចក្តីសម្រេចនេះ។

**ប្រការ២ .–**

បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣ .–**

នាយកខុទ្ទកាល័យ អគ្គនាយកអភិវឌ្ឍន៍ទេសចរណ៍និងសហប្រតិបត្តិការអន្តរជាតិ អគ្គាធិការ ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ផលិតផលទេសចរណ៍ ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងទេសចរណ៍ ប្រធានមន្ទីរទេសចរណ៍រាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រី**

**ថោង ខុន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- គណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- មន្ទីរទេសចរណ៍រាជធានី ខេត្ត
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធ
## នីតិវិធីប្រតិបត្តិស្តង់ដារអប្បបរមា ( Minimum Standard of Operation - MSOP )
## តាមគន្លងប្រក្រតីភាពថ្មីសម្រាប់អាជីវកម្មរមណីយដ្ឋានទេសចរណ៍

តាមរយៈការដាក់ចេញនូវវិធានការជាបន្តបន្ទាប់របស់រាជរដ្ឋាភិបាលក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ពិសេសវិធានសុវត្ថិភាពទេសចរណ៍របស់ក្រសួងទេសចរណ៍ ចលនាទេសចរណ៍ផ្ទៃក្នុងទៅកាន់តំបន់រមណីយដ្ឋានទេសចរណ៍នានា បានបង្ហាញនូវភាពធន់នឹងវិបត្តិ (Resilient) និងបង្កើតបានជាប្រាក់ចំណូលជូនប្រជាពលរដ្ឋ និងវិស័យឯកជន រួមចំណែកទ្រទ្រង់វិស័យទេសចរណ៍ និងកាត់បន្ថយផលប៉ះពាល់នៃការធ្លាក់ចុះនៃភ្ញៀវទេសចរអន្តរជាតិ ពិសេសរួមចំណែកទ្រទ្រង់ដល់ការបន្តសកម្មភាពទេសចរណ៍ និងសេដ្ឋកិច្ចនៅតាមមូលដ្ឋាន។

ក្នុងន័យនេះ នីតិវិធីប្រតិបត្តិស្តង់ដារអប្បបរមា (MSOP) សម្រាប់អាជីវកម្មរមណីយដ្ឋានទេសចរណ៍ត្រូវបានរៀបចំឡើងដោយផ្អែកលើអភិក្រមចំនួនពីរគឺ **ទី១) រក្សាសុវត្ថិភាព និងសុខភាពសាធារណៈរបស់អ្នកផ្គត់ផ្គង់ និងអ្នកប្រើប្រាស់សេវាក្នុងរមណីយដ្ឋាន និងទី២) ធានានូវទំនុកចិត្ត និងភាពពេញចិត្តរបស់ភ្ញៀវទេសចរក្នុងការដើរកម្សាន្តនៅតាមរមណីយដ្ឋានទេសចរណ៍នានាទូទាំងប្រទេស។**

នីតិវិធីប្រតិបត្តិស្តង់ដារអប្បបរមាសម្រាប់អាជីវកម្មរមណីយដ្ឋានទេសចរណ៍ ផ្តោតលើចំណុចសំខាន់ចំនួន ៦ រួមមាន៖

១. ការគ្រប់គ្រងចរន្តភ្ញៀវទេសចរ
២. ការរៀបចំវិធានសុវត្ថិភាពទេសចរណ៍ក្នុងរមណីយដ្ឋានទេសចរណ៍
៣. ការធានាសុវត្ថិភាព និងសុខភាពសាធារណៈភ្ញៀវទេសចរ
៤. ការធានាសុវត្ថិភាព និងសុខភាពសាធារណៈបុគ្គលិកបម្រើការ
៥. ការជំរុញផ្សព្វផ្សាយវិធានការក្នុងការទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩
៦. ការចូលរួមអនុវត្តគោលនយោបាយនានារបស់រាជរដ្ឋាភិបាល

### ១. ការគ្រប់គ្រងចរន្តភ្ញៀវទេសចរ

- រមណីយដ្ឋានទេសចរណ៍ត្រូវរៀបចំឱ្យមានគណៈគ្រប់គ្រង ឬក្រុមការងារគ្រប់គ្រងរមណីយដ្ឋាន (Site Manager) ឱ្យបានច្បាស់លាស់
- រមណីយដ្ឋានទេសចរណ៍ត្រូវកំណត់អំពីសមត្ថភាពផ្ទុកអតិបរមា (Carrying Capacity) ដែលរមណីយដ្ឋានទេសចរណ៍អាចទទួលភ្ញៀវទេសចរបានក្នុងមួយពេល និងមិនត្រូវទទួលភ្ញៀវលើសពីចំណុះនេះជាដាច់ខាត
- រមណីយដ្ឋានទេសចរណ៍ត្រូវរៀបចំច្រកទ្វារចូលរមណីយដ្ឋានឱ្យបានសមរម្យ ដើម្បីធ្វើសម្រង់ព័ត៌មានភ្ញៀវទេសចរទាំងអស់ដែលចូលកម្សាន្តក្នុងរមណីយដ្ឋាន ជាពិសេសកត់ត្រាអាសយដ្ឋាន និងលេខទំនាក់ទំនងភ្ញៀវទេសចរទាំងអស់ឱ្យបានម៉ត់ចត់
- រមណីយដ្ឋានទេសចរណ៍ត្រូវចុះឈ្មោះបង្កើត និងប្រើប្រាស់ប្រព័ន្ធ QR Code ទប់ស្កាត់កូវីដ-១៩ និងតម្រូវឱ្យភ្ញៀវទេសចរត្រូវតែស្កេនជាដាច់ខាត មុនចូលទៅក្នុងកន្លែងរបស់ខ្លួន

- រមណីយដ្ឋានទេសចរណ៍ត្រូវកំណត់ទីតាំងក្នុងរមណីយដ្ឋានទេសចរណ៍ ដែលភ្ញៀវទេសចរអាចប្រើប្រាស់រួមគ្នាបាន ដូចជាកន្លែងកម្សាន្ត កន្លែងទទួលទានអាហារ និងបន្ទប់ទឹកជាដើម
- រមណីយដ្ឋានទេសចរណ៍ត្រូវរៀបចំបញ្ចៀសការជួបជុំជាក្រុមធំ និងត្រូវរក្សាគំលាតសុវត្ថិភាពឱ្យបានត្រឹមត្រូវតាមការណែនាំរបស់ក្រសួងសុខាភិបាល
- ត្រូវរៀបចំគំនូសបែងចែកគន្លងធ្វើដំណើររបស់ភ្ញៀវទេសចរនៅតាមទីតាំងដែលចាំបាច់ ដើម្បីបញ្ចៀសការកកកុញ ឬការជួបជុំមនុស្សច្រើនដោយចៃដន្យ
- ត្រូវជំរុញលើកទឹកចិត្តភ្ញៀវទេសចរឱ្យទៅលំហែកម្សាន្តជាមួយធម្មជាតិ និងសក្តានុពលដែលមានក្នុងរមណីយដ្ឋាន ដើម្បីបញ្ចៀសការជួបជុំទ្រង់ទ្រាយធំ
- រមណីយដ្ឋានទេសចរណ៍ត្រូវខិតខំជំរុញការគ្រប់គ្រង និងអភិវឌ្ឍរមណីយដ្ឋានទេសចរណ៍ក្នុង "គន្លងប្រក្រតីភាពថ្មី"

## ២. ការរៀបចំវិធានសុវត្ថិភាពទេសចរណ៍ក្នុងរមណីយដ្ឋានទេសចរណ៍

- រមណីយដ្ឋានទេសចរណ៍ត្រូវពង្រឹងការអនុវត្តឱ្យបានយ៉ាងខ្ជាប់ខ្ជួននូវវិធានការទាំងឡាយ ដែលបានដាក់ចេញដោយរាជរដ្ឋាភិបាលក្នុងការទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩
- រមណីយដ្ឋានទេសចរណ៍ត្រូវរៀបចំឱ្យមានការត្រួតពិនិត្យកំដៅគ្រប់ភ្ញៀវទេសចរដែលត្រូវចូលទៅកម្សាន្តនៅតាមរមណីយដ្ឋានទេសចរណ៍
- រមណីយដ្ឋានទេសចរណ៍ត្រូវរៀបចំឱ្យមានការបាញ់អាល់កុលសំលាប់មេរោគមុននឹងចូលកម្សាន្តក្នុងរមណីយដ្ឋាន
- រមណីយដ្ឋានទេសចរណ៍ត្រូវរៀបចំឱ្យមានអាល់កុលបាញ់សំលាប់មេរោគ និងសម្រាប់លាងដៃឱ្យបានគ្រប់គ្រាន់ និងគ្រប់ទីកន្លែងដែលចាំបាច់
- រមណីយដ្ឋានទេសចរណ៍ត្រូវធ្វើការសំអាតឱ្យបានជាប្រចាំបន្ទប់ទឹក បរិវេណ និងទីតាំងនានាដែលភ្ញៀវទេសចរបានប៉ះពាល់
- រមណីយដ្ឋានទេសចរណ៍ត្រូវណែនាំឱ្យភ្ញៀវទេសចរលាងសំអាតដៃជាប្រចាំ និងរាល់ពេលដែលចាប់កាន់វត្ថុថ្មី
- រមណីយដ្ឋានទេសចរណ៍ត្រូវរៀបចំឱ្យមានបុគ្គលិកប្រចាំការដើម្បីណែនាំភ្ញៀវទេសចរឱ្យអនុវត្តតាមវិធានសុវត្ថិភាពក្នុងការទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ មុនពេលចូលកម្សាន្តក្នុងរមណីយដ្ឋាន
- រមណីយដ្ឋានទេសចរណ៍ត្រូវខិតខំរៀបចំឱ្យមានលំហបើកទូលាយ (Open Space) ឱ្យបានច្រើនកន្លែងនៅក្នុងរមណីយដ្ឋាន
- រមណីយដ្ឋានទេសចរណ៍ដែលផ្តល់សេវាស្នាក់នៅ ម្ហូបអាហារ និងសេវាផ្សេងៗទៀតជូនភ្ញៀវទេសចរត្រូវអនុវត្តតាមវិធានសុវត្ថិភាពទេសចរណ៍នៃសេវានោះ ដែលដាក់ចេញដោយក្រសួងទេសចរណ៍
- រមណីយដ្ឋានទេសចរណ៍ត្រូវជំរុញការប្រើប្រាស់បច្ចេកវិទ្យាក្នុងដំណើរការអាជីវកម្ម និងការប្រកបសកម្មភាពនានាក្នុងរមណីយដ្ឋាន ដូចជាការបំពាក់កាមេរ៉ាសុវត្ថិភាព ការបញ្ជាទិញ ការប្រើប្រាស់សេវាផ្សេងៗក្នុងរមណីយដ្ឋាន និងការទូទាត់ប្រាក់តាមប្រព័ន្ធបច្ចេកវិទ្យាជាដើម។

## ៣. ការធានាសុវត្ថិភាព និងសុខភាពសាធារណៈភ្ញៀវទេសចរ

- ភ្ញៀវទេសចរត្រូវអនុវត្តឱ្យបានយ៉ាងខ្ជាប់ខ្ជួននូវវិធានការទាំងឡាយ ដែលបានដាក់ចេញដោយរាជរដ្ឋាភិបាលក្នុងការទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ ពិសេសវិធានការ "៣ ការពារ និង ៣ កុំ"
- ភ្ញៀវទេសចរត្រូវចូលរួមប្រើប្រាស់ប្រព័ន្ធ QR Code ទប់ស្កាត់កូវីដ-១៩ និងត្រូវស្កេនជាដាច់ខាតមុនចូលទៅក្នុងរមណីយដ្ឋាន
- ភ្ញៀវទេសចរត្រូវត្រួតពិនិត្យកំដៅមុនពេលចូលទៅកម្សាន្តនៅក្នុងរមណីយដ្ឋានទេសចរណ៍
- ភ្ញៀវទេសចរត្រូវពាក់ម៉ាស់ឱ្យបានជាប្រចាំ
- ភ្ញៀវទេសចរត្រូវបានលើកទឹកចិត្តឱ្យបញ្ចៀសការជួបជុំជាក្រុមធំ និងត្រូវរក្សាគំលាតសុវត្ថិភាពឱ្យបានត្រឹមត្រូវតាមការណែនាំ របស់ក្រសួងសុខាភិបាល
- ភ្ញៀវទេសចរត្រូវបានលើកទឹកចិត្តឱ្យទៅលំហែកម្សាន្តជាមួយធម្មជាតិ និងសក្តានុពលដែលមានក្នុងរមណីយដ្ឋានទេសចរណ៍ ដើម្បីបញ្ចៀសការជួបជុំទ្រង់ទ្រាយធំ។

## ៤. ការធានាសុវត្ថិភាព និងសុខភាពសាធារណៈបុគ្គលិកបម្រើការ

- បុគ្គលិកបម្រើការក្នុងរមណីយដ្ឋានត្រូវទទួលការចាក់វ៉ាក់សាំងគ្រប់ចំនួនដូសតាមការណែនាំរបស់ក្រសួងសុខាភិបាល
- បុគ្គលិកបម្រើការក្នុងរមណីយដ្ឋាន ត្រូវទទួលបានការបណ្តុះបណ្តាលអំពីវិធានការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩នេះ
- បុគ្គលិកបម្រើការក្នុងរមណីយដ្ឋាន ត្រូវទទួលបានការបណ្តុះបណ្តាលអំពីសេវាកម្មទេសចរណ៍ និងការធ្វើបដិសណ្ឋារកិច្ចប្រកបដោយស្តង់ដា
- បុគ្គលិកបម្រើការក្នុងរមណីយដ្ឋាន ត្រូវអនុវត្តជាគំរូ និងជាប្រចាំក្នុងពេលបំពេញការងារនូវរាល់វិធានការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩
- គ្រប់បុគ្គលិកបម្រើការក្នុងរមណីយដ្ឋាន ត្រូវពន្យល់ណែនាំអំពីវិធានការទប់ស្កាត់ជំងឺកូវីដ-១៩ ទៅដល់ភ្ញៀវទេសចរ និងដៃគូពាក់ព័ន្ធ និងត្រូវឱ្យភ្ញៀវទេសចរ និងដៃគូពាក់ព័ន្ធចូលរួមអនុវត្តជាកាតព្វកិច្ច។ ក្នុងករណីភ្ញៀវទេសចរ និងដៃគូពាក់ព័ន្ធ ពុំអនុវត្តតាមត្រូវរាយការណ៍ទៅគណៈគ្រប់គ្រងរមណីយដ្ឋាន ដើម្បីមានវិធានការបន្ត
- រមណីយដ្ឋានទេសចរណ៍ត្រូវលើកទឹកចិត្តឱ្យបុគ្គលិកទាំងអស់រាយការណ៍អំពីស្ថានភាពសុខភាពរបស់ខ្លួនជាប្រចាំដើម្បីបញ្ចៀសហានិភ័យនៃការចំលងជំងឺកូវីដ-១៩ ជាយថាហេតុ

## ៥. ការជំរុញផ្សព្វផ្សាយវិធានការក្នុងការទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩

- រមណីយដ្ឋានទេសចរណ៍ត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវវិធានការទាំងឡាយ ដែលបានដាក់ចេញដោយរាជរដ្ឋាភិបាលក្នុងការទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ តាមគ្រប់រូបភាពទៅដល់ភាគីពាក់ព័ន្ធ ពិសេសភ្ញៀវទេសចរ បុគ្គលិកបម្រើការ និងអ្នកផ្គត់ផ្គង់សេវាផ្សេងៗ
- រមណីយដ្ឋានទេសចរណ៍ត្រូវលើកស្លាកសញ្ញាស្តីពីគ្រោះថ្នាក់ និងវិធានការទប់ស្កាត់ជំងឺកូវីដ-១៩ ពិសេសវិធានការ "៣ ការពារ និង ៣ កុំ" នៅតាមទីតាំងសំខាន់ៗក្នុងរមណីយដ្ឋាន

- សហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍ត្រូវបិទផ្សាយបណ្ណពត៌មាន និងសេចក្តីប្រកាសនានា អំពីវិធានការរបស់រាជរដ្ឋាភិបាល និងក្រសួងទេសចរណ៍ ក្នុងការទប់ស្កាត់ការរីករាលនៃជំងឺកូវីដ១៩

**៦. ការចូលរួមអនុវត្តគោលនយោបាយនានារបស់រាជរដ្ឋាភិបាល**

- សហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍ត្រូវពង្រឹងការអនុវត្តឲ្យបានយ៉ាងខ្ជាប់ខ្ជួននូវវិធានការទាំងឡាយ ដែលបានដាក់ចេញដោយរាជរដ្ឋាភិបាលក្នុងការទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩
- សហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍ត្រូវចុះឈ្មោះបង្កើត និងប្រើប្រាស់ប្រព័ន្ធ QR Code ទប់ស្កាត់កូវីដ-១៩ សម្រាប់ប្រើប្រាស់ក្នុងសហគមន៍
- សហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍ត្រូវជំរុញការអនុវត្តនូវគោលនយោបាយនានារបស់រាជរដ្ឋាភិបាលក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ពិសេសគាំទ្រដល់គោលនយោបាយចាក់វ៉ាក់សាំងរបស់រាជរដ្ឋាភិបាល តាមរយៈការដាក់ចេញនូវយុទ្ធសាស្ត្រ និងសកម្មភាពជាក់ស្តែង។
- សហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍គួរមានកម្មវិធីលើកទឹកចិត្តភ្ញៀវទេសចរដែលបានចាក់វ៉ាក់សាំងគ្រប់ចំនួនដូសតាមការណែនាំរបស់ក្រសួងសុខាភិបាល។